**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១១៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានៈវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ឱ្យមានឋានៈស្មើថ្នាក់អគ្គនាយកដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១.-**

ដំឡើងឋានៈវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ឱ្យមានឋានៈស្មើថ្នាក់អគ្គនាយកដ្ឋាននៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា២.-**

វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស មានភារកិច្ច៖

- រៀបចំអភិវឌ្ឍន៍កម្មវិធីសិក្សាតាមបែបការបណ្តុះបណ្តាល ផ្អែកលើសមត្ថភាពសម្រាប់ការប្រើប្រាស់ក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទូទាំងប្រទេស។
- បណ្តុះបណ្តាល និងវិក្រឹត្យការសាស្ត្រាចារ្យ គ្រូអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

- បណ្តុះបណ្តាលការងារគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដល់ថ្នាក់គ្រប់គ្រង។
- បណ្តុះបណ្តាលធនធានមនុស្សចាប់ពីកម្រិតបឋមបច្ចេកទេស រហូតដល់កម្រិតក្រោយឧត្តមបច្ចេកទេស តាមប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ស្របតាមការអភិវឌ្ឍរបស់ប្រទេសជាតិ។
- ស្រាវជ្រាវពីគោលការណ៍បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈអន្តរជាតិ ពិសេសក្នុងតំបន់ ដើម្បីរួមចំណែកតម្រង់ទិសដៅបណ្តុះបណ្តាល ឱ្យសមស្របទៅតាមតម្រូវការទីផ្សារពលកម្ម។
- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗ រួមចំណែកអភិវឌ្ឍន៍សហគមន៍។

**មាត្រា៣.-**

នាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស មានឋានៈស្មើនឹងអគ្គនាយក និងមាននាយករងមួយចំនួនមានឋានៈស្មើនឹងអគ្គនាយករងជាជំនួយការ តាមការចាំបាច់។

**មាត្រា៤.-**

ចំពោះមុខ វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស មានៈ

- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
- ផ្នែកអភិវឌ្ឍន៍កម្មវិធីសិក្សា
- ផ្នែកអភិវឌ្ឍន៍ធនធានសិក្សា
- ផ្នែកបច្ចេកទេស
- ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងទំនាក់ទំនងអន្តរជាតិ
- ដេប៉ាតឺម៉ង់វិស្វកម្មសំណង់ស៊ីវិល
- ដេប៉ាតឺម៉ង់វិស្វកម្មអគ្គិសនី និងអេឡិចត្រូនិច
- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ដេប៉ាតឺម៉ង់ស្រាវជ្រាវ និងផែនការស្ថិតិ
- ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា

ទៅអនាគត វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស នឹងអាចបង្កើតផ្នែកនិងដេប៉ាតឺម៉ង់ជំនាញឯកទេសមួយចំនួនទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ប្រធានផ្នែក និងដេប៉ាតឺម៉ង់ មានឋានៈស្មើប្រធាននាយកដ្ឋាន។

**មាត្រា៥.-**

វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស កាន់កាប់ និងប្រើប្រាស់គណនេយ្យ តាមប្រព័ន្ធគណនេយ្យសាធារណៈដែលបានឧបត្ថម្ភពីថវិកាជាតិ សម្រាប់បណ្តុះបណ្តាល និងមានខ្ទង់គណនេយ្យដោយឡែក។

**មាត្រា៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ